# “ពួកគេបោកប្រាស់យើងគ្រប់ជំហាន”

## ការរំលោភលើអ្នកធ្វើការតាមផ្ទះជាតិកម្ពុជា ដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី



មណ្ឌលហ្វឹកហ្វឺនក្នុងរាជធានីភ្នំពេញ ដែលមានម្ចាស់ និងគ្រប់គ្រងដោយទីភ្នាក់ងារជ្រើសរើស ពលករឯកជន សម្រាប់ពលករធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី។ ការស្រាវជ្រាវ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា ពលករចំណាកស្រុកដែលត្រៀមចាកចេញ ជាធម្មតាត្រូវបានគេចាក់សោឲ្យនៅតែក្នុងមណ្ឌលហ្វឹកហ្វឺនទាំងនេះ ចំនួនបីខែទៅប្រាំមួយខែ មុនពេលចាកចេញ។ សិក្ខាកាមជាញឹកញយ មិនមានសិទ្ធិទទួលបានការថែទាំសុខភាព អាហារហូបចុក និងទឹកហូបគ្រប់គ្រាន់ទេ នៅក្នុងមណ្ឌល។ ស្ត្រីនិងកុមារីមួយចំនួនទទួលរង ការរំលោភបំពានតាមរយៈ ពាក្យសម្តី ផ្លូវចិត្ត និងជូនកាលផ្លូវកាយ។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

# សេចក្តីសង្ខេប

> មេខ្យល់ម្នាក់បាននិយាយថា ក្រុមហ៊ុនកំពុងតែរកស្ត្រីយកទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។ នៅពេលដែលខ្ញុំសួរថាតើមានអ្នកជួយកូនស្រីរបស់ខ្ញុំដែរឬទេ ប្រសិនកូនស្រីខ្ញុំមានបញ្ហា។ មេខ្យល់និយាយថា ប្រសិនបើមានរឿងអីកើតឡើងចំពោះកូនស្រីខ្ញុំ ឧទាហរណ៍បើសិនជា នាង ស្លាប់ ក្រុមហ៊ុននឹងចេញសង ... មេខ្យល់និយាយថា "បងឯងអាចសម្រាកដោយមិនចាំបាច់ ធ្វើការងារអីទេ អស់មួយជីវិត ជាមួយនឹងប្រាក់សំណងនោះ ។"
>
> — ញាន ជាឪពុករបស់នាងចំប៉ី ដែលជាពលករធ្វើការតាមផ្ទះ អាយុ២១ ឆ្នាំ ដែល បានស្លាប់នៅក្នុងមណ្ឌលហ្វឹកហ្វឺនរាជធានីភ្នំពេញរបស់ក្រុមហ៊ុន វីស៊ី ម៉ែនផាវឺ ប្រទេសកម្ពុជា ខែមេសា ឆ្នាំ២០១១។

ខណៈពេលដែល ញុន យ៉ាណា អាយុ១៦ឆ្នាំ បានធ្វើចំណាកស្រុកពីកម្ពុជាទៅកាន់ម៉ាឡេស៊ីជាអ្នកធ្វើការនៅតាមផ្ទះក្នុងឆ្នាំ២០១០ អ្វីដែលជាសេចក្តីសង្ឃឹមរបស់នាងនោះគឺការរកប្រាក់មួយចំនួនមកជួយបងប្អូនប្រុសស្រីរបស់នាង ម្តាយដែលកំពុងតែឈឺ និងជីដូនដែលចាស់ជរា។ មេខ្យល់បានសន្យាឲ្យការងារមួយទៅនាង ដែលការងារនោះងាយស្រួល ហើយនាងនឹងបានទទួលប្រាក់ ៣,០០០ដុល្លារ ក្នុងរយៈពេលពីរឆ្នាំ។ ប៉ុន្តែអ្វីៗបានក្លាយទៅជារឿងជូចត់ យ៉ាងឆាប់រហ័ស បន្ទាប់ពីនាងបានចុះហត្ថលេខាជាមួយទីភ្នាក់ងារជ្រើសរើសពលករមួយ ដែលភ្លាមៗនោះបានបង្ខាំងនាងទុកក្នុងមណ្ឌលហ្វឹកហ្វឺនរាជធានីភ្នំពេញអស់រយៈពេលបីខែ និងបានបដិសេធការទាក់ទងជាមួយគ្រួសាររបស់នាង។ បន្ទាប់ពីនាងបានទៅដល់ប្រទេស ម៉ាឡេស៊ី អ្នកជួលនាងបានឲ្យការងារនាងធ្វើ ដែលការងារនោះទាល់តែប្រើមនុស្សច្រើននាក់ ទើបអាចធ្វើបាន។

> ខ្ញុំងើបនៅម៉ោង ៤ ព្រឹក សម្អាតផ្ទះរបស់ថៅកែខ្ញុំ លាងរថយន្តទាំងពីររបស់គាត់ ងូតទឹកនិងបញ្ចុកអាហារកូនក្មេង... ក្រោយមកខ្ញុំធ្វើការសំអាតនៅក្នុងការិយាល័យរបស់គាត់ និងសម្អាតបន្ទប់ចំនួន ៤ ជូតតុនិងកម្រាលឥដ្ឋ។ បន្ទាប់ពីនោះមក គាត់បានយកខ្ញុំទៅផ្ទះម្តាយរបស់គាត់ ដែលនៅទីនោះខ្ញុំធ្វើការរហូតដល់ម៉ោង ៩ យប់។ ក្រោយមក ខ្ញុំត្រឡប់មកផ្ទះថៅកែរបស់ខ្ញុំវិញ និងធ្វើការរហូតដល់ម៉ោង ២ ព្រឹក ប៉ុន្តែគេនៅតែវាយខ្ញុំ។ គេនិយាយថា ខ្ញុំខ្ជិល។ ពួកគេអត់ឲ្យអាហារខ្ញុំហូបទេ។ ខ្ញុំដេកដោយអត់បានបាយហូប ពីរឬបីដងក្នុងមួយ សប្តាហ៍។

ទោះបីជា យ៉ាណា បានធ្វើការប្រាំបីខែហើយក៏ដោយ ក៏នាងមិនដែលបានទទួលប្រាក់ខែរបស់ នាងទេ។ នាងបានរត់ចេញពីផ្ទះថៅកែរបស់នាង និងទីបំផុតអង្គការក្រៅរដ្ឋាភិបាលមួយក៏បានជួយនាងឲ្យត្រលប់មកប្រទេសកម្ពុជាវិញ។




ស្រ្តីម្នាក់បង្ហាញរូបថតសាច់ញាតិរបស់គាត់ ដែលមិនបានទាក់ទងមកគ្រួសារចាប់តាំងពីពេល នាងបានធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី ក្នុងខែកញ្ញា ឆ្នាំ២០០៩។ គាត់និយាយថា  សាច់ញាតិ របស់គាត់ចង់ធ្វើជាអ្នកធ្វើការតាមផ្ទះនៅប្រទេសម៉ា ឡេស៊ី ដើម្បីរកប្រាក់មក សង់ផ្ទះមួយឲ្យគ្រួសារ របស់នាងក្នុងប្រទេសកម្ពុជា។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

នៅក្នុងប្រទេសកម្ពុជា រឿងបែបនេះមានលក្ខណៈសាមញ្ញទៅហើយ។ ប្រជាពលរដ្ឋកម្ពុជាជាច្រើនកំពុងតែតស៊ូដើម្បីរស់ ដោយមានប្រជាពលរដ្ឋមួយភាគបីដែលកំពុងរស់នៅក្រោមបន្ទាត់ ក្រីក្រជាតិ ដោយមានចំណូល ៦១សេនដុល្លារអាមេរិកក្នុងមួយថ្ងៃ។ ភាពក្រីក្រមានច្រើនខ្លាំងហួសហេតុបំផុតនៅតំបន់ជនបទ។ នៅតំបន់អ្នកក្រីក្របំផុត និងតំបន់អ្នកដែលគេមិនសូវគិតគូរដល់ក្នុងសង្គមកម្ពុជា ស្ត្រីគឺជាអ្នកដែលប្រឈមមុខទល់នឹងការរើសអើងច្រើនជាងគេបំផុត។ តាំងតែពីមុនមកដល់ឥឡូវនេះ ស្ត្រីនៅតែទទួលរែកពន់រកប្រាក់ចិញ្ចឹមគ្រួសារ។ ខណៈដែល ស្ត្រីមួយចំនួនតូចមានឱកាសនៅផ្ទះ មានស្ត្រីនិងកុមារីជាច្រើនធ្វើចំណាកស្រុកទៅក្រៅ ប្រទេសក្នុងនាមជាអ្នកធ្វើការតាមផ្ទះ ដែលភាគច្រើនទៅប្រទេសម៉ាឡេស៊ី។ ស្ត្រីនិងកុមារី រវាង ពី បួនម៉ឺន ទៅ ប្រាំម៉ឺននាក់ បានធ្វើដំណើរទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីធ្វើការងារតាមផ្ទះ។

តម្រូវការនៃការរកអ្នកធ្វើការតាមផ្ទះជាតិកម្ពុជា មានកំណើនច្រើនឡើងយ៉ាងខ្លាំងនៅក្នុង ប្រទេសម៉ាឡេស៊ី ចាប់តាំងពីឆ្នាំ២០០៩មក ខណៈពេលដែលរដ្ឋាភិបាលឥណ្ឌូនេស៊ី បានឆ្លើយ តបចំពោះអំពើរំលោភធ្ងន់ធ្ងរ ដោយបានដាក់នូវការផ្អាកជាបណ្តោះអាសន្នចំពោះប្រជាពលរដ្ឋ របស់ខ្លួនក្នុងការធ្វើការងារជាអ្នកបម្រើការតាមផ្ទះនៅទីនោះ។ ទីភ្នាក់ងារជ្រើសរើសពលករ ភ្លាមៗនោះ បានងាកមករកអ្នកធ្វើការពីប្រទេសកម្ពុជា ដើម្បីបំពេញការខ្វះខាតនោះ។

ការផ្តល់ប្រាក់ឲ្យមុនដ៏ច្រើនដល់គ្រួសារទីទាល់ក្រ ប្រាក់ឈ្នួលដែលមានកម្រិតច្រើនហួសពីអ្វីដែលអាចរកបាននៅក្នុងភូមិ និងការសន្យាផ្តល់ការងារធ្វើនៅតាមផ្ទះជាជាងការងារនៅតាមហាងដែលធ្វើការងារច្រើនម៉ោងហើយទទួលបានកម្រៃតិចតួច ឬនៅតាមផ្ទះបន គឺជាការទាក់ទាញទឹកចិត្តយ៉ាងខ្លាំង។ មានស្ត្រីកម្ពុជាដែលមានបទពិសោធន៍ការងារច្បាស់លាស់ ក្នុង ប្រទេសម៉ាឡេស៊ី ហើយដែលប្រាក់កម្រៃរបស់ពួកគេបានចូលរួមចំណែកយ៉ាងច្រើនដល់ ចំណូលរបស់គ្រួសារ។

ក៏ប៉ុន្តែ ក្តីសង្ឃឹមទាំងលំបាករួចទៅហើយអំពីការធ្វើចំណាកស្រុកទៅកាន់បរទេស ការរស់នៅ ឃ្លាតឆ្ងាយពីផ្ទះសម្បែងនិងដោយមិនបានទាក់ទងជាមួយគ្រួសារ គឺជាស្ថានភាពដ៏អាក្រក់មួយ ដែលជាញឹកញយត្រូវបានធ្វើអោយកាន់តែអាក្រក់ឡើងដោយ ការអនុវត្តមិនល្អនិងមិនត្រឹមត្រូវ តាមច្បាប់របស់ទីភ្នាក់ងារជ្រើសរើសពលករដែលខកខានមិនបានបង្ហាញអោយពលករបាន ដឹងអំពីការងារនានា ដែលពួកគេរំពឹងថានឹងត្រូវធ្វើ និងការខ្វះខាតថ្ងៃឈប់សម្រាករបស់ពួកគេ ព្រមទាំងយន្តការផ្តល់ជំនួយដល់ពួកគេនៅពេលពួកគេប្រឈមនឹងបញ្ហាឬការរំលោភបំពាន។ ជាលទ្ធផល ស្ត្រីនិងកុមារីកម្ពុជាងាយនឹងទទួលរងនូវបទពិសោធនៃការឈឺចាប់ ដ៏អាក្រក់ និងភាពឯកោក្នុងប្រទេសម៉ាឡេស៊ី។

របាយការណ៍នេះ ផ្អែកលើការស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា និងប្រទេស ម៉ាឡេស៊ី ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០១១ - រាប់បញ្ចូលការសម្ភាសន៍ចំនួន ៨០ ជាមួយ អ្នកធ្វើការតាមផ្ទះ មន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករ - រកឃើញ ការរំលោភនៅ

គ្រប់ដំណាក់កាលទាំងអស់ក្នុងរង្វង់នៃការធ្វើចំណាកស្រុក សម្រាប់ អ្នកធ្វើការតាមផ្ទះជាតិកម្ពុជា ដោយមានការផ្តល់កិច្ចការពារតិចតួច ឬមិនមានការការពារទាល់ តែសោះពីរដ្ឋាភិបាលកម្ពុជា។

ទីភ្នាក់ងារជ្រើសរើសពលករឯកជនក្នុងប្រទេសកម្ពុជា ត្រួតត្រាកិច្ចដំណើរការនៃការធ្វើចំណាកស្រុកស្ទើគ្រប់ទិដ្ឋភាពទាំងអស់ មានជាអាទិ៍ដំណើរការជ្រើសរើសអ្នកធ្វើការតាមផ្ទះ ការហ្វឹក ហ្វឺន ការរកទីកន្លែងធ្វើការងារអោយពលករ ការបញ្ជូនពលករទៅធ្វើការ និងការបញ្ជូនពលករ ត្រឡប់មកវិញ។ តាមរយៈការដាក់ឲ្យជាប់បំណុល ការបង្ខាំងទាំងបង្ខំជាច្រើនខែក្នុងមណ្ឌល ហ្វឹកហ្វឺន និងការគំរាមកំហែងភ្នាក់ងារពលករមួយចំនួន បង្ខំឲ្យស្ត្រី និងកុមារធ្វើចំណាកស្រុក ទោះបីជាពួកគេលែងចង់ទៅធ្វើការនៅក្រៅប្រទេសតទៅទៀតយ៉ាងណាក៏ដោយ។

នៅពេលដែលពួកគេទៅដល់ប្រទេសម៉ាឡេស៊ី អ្នកធ្វើការតាមផ្ទះចំណាកស្រុកពីប្រទេស កម្ពុជា ប្រថុយប្រថាននឹងការកេងប្រវ័ញ្ចលើពលកម្ម និងការរំលោភបំពានជាច្រើន មានជាអាទិ៍ ការមិនឲ្យប្រាក់បៀវត្សរ៍ម៉ោងធ្វើការច្រើនហួសហេតុដោយឲ្យសម្រាកតិចតួច ការរំលោភលើ ផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទពេលស្ថិតក្នុងដៃរបស់និយោជក។

អ្នកធ្វើការតាមផ្ទះដែលទទួលរងការរំលោភបំពាន មានឱកាសតិចតួចដើម្បីស្វែងរកអោយមាន ការដោះស្រាយទាំងក្នុងប្រទេសម៉ាឡេស៊ី ឬប្រទេសកម្ពុជា។ ទោះបីជាមានការស្លាប់ស្ត្រីបីរូប ក្នុងមណ្ឌលហ្វឹកហ្វឺននាឆ្នាំកន្លងមកនេះក្តី មានបណ្តឹងដែលបានដាក់ជូនផ្ទាល់ទៅរដ្ឋាភិបាលក្តី និងមានរបាយការណ៍ដែលគួរជឿបានស្តីពីការជ្រើសរើសពលករជាកុមារ ការរំលោភបំពាន ក្នុងមណ្ឌលហ្វឹកហ្វឺន និងការអនុវត្តនានាពាក់ព័ន្ធនឹងការដាក់ឲ្យជាប់បំណុលទាសភាពក្តី ក៏ រដ្ឋាភិបាលកម្ពុជាមិនបានចាត់វិធានការម៉ឺងម៉ាត់ដើម្បីស៊ើបអង្កេតឲ្យបានពេញលេញ ឬដាក់ ទណ្ឌកម្មជនដែលទទួលខុសត្រូវឡើយ។ ករណីទីមួយដែលមានការកាត់ទោសជោគជ័យនោះ គឺកាលពីខែកញ្ញា ឆ្នាំ២០១១ តុលាការកម្ពុជាបានកាត់ទោសអ្នកគ្រប់គ្រងទូទៅម្នាក់របស់ ទីភ្នាក់ងារជ្រើសរើសពលករ ឈ្មោះ វីស៊ីម៉ែនផាវី ដោយកាត់គាត់ឲ្យជាប់គុករយៈពេល ១៣ខែ ចំពោះការឃុំឃាំងពលករមិនទាន់គ្រប់អាយុ។ ប៉ុន្តែរដ្ឋាភិបាលមិនទាន់បានចាប់ និងកាត់ ទោសភ្នាក់ងារជ្រើសរើសពលករដទៃទៀត ដែលពាក់ព័ន្ធក្នុងករណីស្រដៀងគ្នានេះ ហើយក៏ មិនទាន់បានដកហូតអាជ្ញាប័ណ្ណពីទីភ្នាក់ងារជ្រើសរើសពលករណាមួយតែមួយក៏គ្មានដែរ។



ផ្ទះរបស់ភួង (ឈ្មោះពិតត្រូវបានដកចេញ) បានស្លាប់នៅក្នុងមណ្ឌលហ្វឹកហ្វឺនរាជធានីភ្នំពេញ របស់ក្រុមហ៊ុនជ្រើសរើសពលករ ធីអែនភី ។ ស្ត្រីនិងកុមារីជាច្រើនដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី មកពីតំបន់ជនបទ និងពីតំបន់មានប្រវត្តិសេដ្ឋកិច្ចទីទាល់ក្រ។ ភួងចង់ធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីជួយគាំទ្រដល់កូនទាំងបីរបស់នាង។ កូនស្រី បងរបស់នាងមានអាយុ១៧ ឆ្នាំ ក៏បានធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ីផងដែរ។ កូន ដែលនៅសេសសល់ទាំងពីររបស់ភួង កំពុងតែរស់នៅជាមួយញាតិសន្តាន ដែលតស៊ូបង់ថ្លៃ សិក្សារបស់ពួកគេ។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។



ស្ត្រីម្នាក់បានកាន់រូបថតរបស់ប្អូនស្រីរបស់នាង ដែលបានធ្វើចំណាកស្រុកទៅកាន់ប្រទេស ម៉ាឡេស៊ី ដើម្បីជួយគាំទ្រកូនវ័យក្មេងទាំងបីរបស់នាង។ គាត់និយាយថា ប្អូនស្រីរបស់គាត់បាន ទុកកូនបងពីរនាក់ជាមួយញាតិសន្តានម្នាក់ និងកូនអាយុបីឆ្នាំ (រូបភាពខាងលើ) ជាមួយគាត់។ ប្អូនស្រីរបស់គាត់មិនបានទាក់ទងមកសាច់ញាតិណាម្នាក់ទេ តាំងតែពីនាងចាកចេញទៅ ប្រទេសម៉ាឡេស៊ីក្នុងខែមីនា ឆ្នាំ២០១០។ អត់មានសាច់ញាតិណាម្នាក់ដឹងថានាងរស់នៅទី កន្លែងណាពិតប្រាកដទេ ឬអត់ដឹងពីរបៀបទាក់ទងទៅនាងផងដែរ។ © 2011 យូសនា ពូយ៉ាល /អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

# ក្រុមហ៊ុន អិល អេ ធី ខេមបូឌា ខូអិលធីឌី អិលធីឌី

## L.A.T Cambodia Co., Ltd

មជ្ឈមណ្ឌលជ្រើសរើស និងបណ្ដុះ… ពលករខ្មែរទៅបំរើការងារនៅប្រទេសម៉ាឡេស៊ី



## សមត្ថភាពហាត់រៀនរបស់ពលការិនីមុនពេលចេញទៅបំរើការងារ

### អិល អេ ធី

…បានចុះឈ្មោះក្នុងបញ្ជីក្រសួងការងារដើម្បីជ្រើសរើស …ពលការិនីខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ដោយស្របច្បាប់។

១-ក្រុមហ៊ុន…ការិយាល័យផ្ទាល់ខ្លួននៅប្រទេសម៉ាឡេស៊ី ងាយស្រួល …បញ្ជូន និង មើលការខុសត្រូវពលការិនី។

២-ក្រុមហ៊ុនមាន គ្រូបង្រៀនបន្ថែមជាជនជាតិខ្មែរនៅប្រទេសម៉ាឡេស៊ី។

៣-ក្រុមហ៊ុនយើងខ្ញុំទទួលខុសត្រូវ និងការពារសិទ្ធិពលការិនី ស្របតាមច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា និង ម៉ាឡេស៊ី។

៤-ពលការិនីអាចផ្ញើរប្រាក់អោយក្រុមគ្រួសារតាមរយៈក្រុមហ៊ុនផ្ទាល់ នៅម៉ាឡេស៊ី ធានាថាមិនអោយបាត់មួយរៀលឡើយ។

៥-ក្រុមហ៊ុននឹងរៀបចំធ្វើឯកសារនិងលិខិតឆ្លងដែនដល់ពលការិនីទាំងទៅ និងត្រឡប់មកវិញយ៉ាងមានសុវត្ថិភាពត្រឹមត្រូវនិងស្របច្បាប់។

6- ពលការិនីអាចទូរស័ព្ទផ្ដល់ដំណឹង និង សួរសុខទុក្ខក្រុមគ្រួសារ…

✽ចាប់ពីផ្សាយដំណឹងនេះតទៅ ក្រុមហ៊ុនយើងខ្ញុំត្រូវការជ្រើសរើស ពលការិនី ជាច្រើនរយនាក់បន្ថែមទៀត ដើម្បីទៅបំរើការងារជាជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ី ។

### លក្ខខណ្ឌនៃការជ្រើសរើស

-ពលការិនីត្រូវមានអាយុ ចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ

-មិនចេះអក្សរក៏អាចដាក់ពាក្យបានដែរ

-ត្រូវមានអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ រឺ សំបុត្រកំណើត

-ពលការិនីទទួលបានប្រាក់ខែចាប់ពី ១៨០ ទៅ ២៥០ ដុល្លា ស្មើរនឹងលុយខ្មែរ ពី ៧៥០.០០០ ទៅ ១.០៥០.០០០ រៀលក្នុងមួយខែ

-រយៈពេលទៅបំរើការងារ គឺ ២ ឆ្នាំ។


**អាស័យដ្ឋាន:** ផ្ទះលេខ ០៦ ផ្លូវលេខ ៣៣៥ សង្កាត់បឹងកក់១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

Tel: 023 630 70 88 / 092 99 32 98 / 012 82 28 36 / 097 5988 737 / 097 68 83 768

Email : lat.cambodia@ezecom.com.kh



(opposite)
សេចក្តីប្រកាសដែលបានចែកផ្សព្វផ្សាយដល់អ្នកភូមិតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ ដែលមាន រាយមុខសេចក្តីត្រូវការសម្រាប់ការដាក់ពាក្យសុំ។ ទីភ្នាក់ងារជាច្រើនប្រកួតប្រជែង គ្នាជ្រើសរើសរកអ្នកធ្វើការតាមផ្ទះ ដោយផ្តល់គ្រឿងជំរុញទឹកចិត្តជាប្រាក់ កាតទូរស័ព្ទ និង សត្វគោក្របី។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

រូបថតរបស់គ្រួសារពលករដែលបានទទួលអង្ករ ទូរស័ព្ទដៃ និងសត្វគោក្របី ដែលជាគ្រឿង ជំរុញទឹកចិត្តសម្រាប់ការធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី នៅក្នុងទីភ្នាក់ងារជ្រើស រើសពលករកម្ពុជា។ មុខវត្ថុទាំងនេះ តាមពិតជាប្រាក់កម្ចីដែលអ្នកធ្វើចំណាកស្រុកជំពាក់ពី ពេលមុនក្នុងដំណើរការនៃការជ្រើសរើសពលករ។ ការគាបសង្កត់ឲ្យសងប្រាក់កម្ចីទាំងនេះ អាចធ្វើឲ្យពលករចំណាកស្រុកជាប់ខ្លួនក្នុងស្ថានភាពរំលោភបំពាន ដែលមានក្នុងមណ្ឌល ហ្វឹកហ្វឺនក្នុងប្រទេសកម្ពុជា ឬនៅកន្លែងធ្វើការងារក្នុងប្រទេសម៉ាឡេស៊ី។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស

ចំណាប់អារម្មណ៍របស់រដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយការងារចំណាកស្រុក ព្រមគ្នាជាមួយ នឹងកំណត់ត្រាដ៏អាក្រក់របស់រដ្ឋាភិបាល ក្នុងការដាក់អោយទីភ្នាក់ងារជ្រើសរើសពលករ ទទួល ខុសត្រូវចំពោះការរំលោភបំពានលើការងារចំណាកស្រុក បង្កើននូវបរិយាកាសនិទណ្ឌភាព ដែលរឹតតែធ្វើឲ្យមានការរំលោភសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរឡើងចំពោះអ្នកធ្វើការតាមផ្ទះដែល ធ្វើចំណាកស្រុក នៅពេលខាងមុខ។ ជាឧទាហរណ៍ យោងតាមអ្នកធ្វើការងារតាមផ្ទះមួយរូបថា ស្ត្រីពីរនាក់បានប៉ុនប៉ងធ្វើអត្តឃាត នៅពេលដែលទីភ្នាក់ងារជ្រើសរើសពលករ បានច្រានចោល ការស្នើសុំរបស់ពួកគេដើម្បីត្រឡប់ទៅផ្ទះវិញ។

បន្ទាប់មកទីភ្នាក់ងារនោះបានរៀបចំកិច្ចប្រជុំ មួយ ដែលមានការចូលរួមពីមន្ត្រីប៉ូលីសពីររូប។ នាងនិយាយថា "មន្ត្រីប៉ូលីសបានប្រាប់យើងថា ប្រសិនបើយើង [មានបំណង] ធ្វើអត្តឃាត នោះពួកគេនឹងដាក់យើងក្នុងគុក។ ពួកគេបាននិយាយផងដែរថា យើងមិនគួរព្យាយាមលួចរត់ទេ។ ទោះជាយើងលួចរត់បានក៏ដោយ ក៏ប៉ូលីសនឹងតាមរក [យើង] ហើយយើងក៏នៅតែត្រូវគេបញ្ជូនទៅកាន់ប្រទេសម៉ាឡេស៊ី។

ភាពចន្លោះប្រហោងក្នុងច្បាប់ការងាររបស់ប្រទេសម៉ាឡេស៊ី បានដាក់ឲ្យអ្នកធ្វើការតាមផ្ទះ គ្មានកិច្ចការពារ។ ដើម្បីដោះស្រាយការកេងប្រវ័ញ្ចលើអ្នកធ្វើការតាមផ្ទះជាចំណាកស្រុក ចាំបាច់ត្រូវតែមានច្បាប់ និងការឃ្លាំមើលឲ្យបានខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា ដូចគ្នានេះដែរ ត្រូវមានការកែទម្រង់ច្បាប់ការងារក្នុងប្រទេសម៉ាឡេស៊ី និងការទទួលបានសេវាគាំទ្រ និង បណ្តាញសម្រាប់ការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធិភាពនៅក្នុងប្រទេសទាំងពីរ។

# ការជ្រើសរើស

ដំណើរការជ្រើសរើសពលករ ពោរពេញទៅដោយបញ្ហាជាច្រើន។ ការស្រាវជ្រាវរបស់យើង បានរកឃើញថា ទីភ្នាក់ងារជ្រើសរើសពលករ ជ្រើសរើសកុមារនិងស្ត្រីក្មេងៗក្រោមអាយុ អប្បរមា ២១ ឆ្នាំ ដើម្បីធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី និងសម្របសម្រួលការរៀបចំ ក្លែងឯកសារអត្តសញ្ញាណនានា។ ភ្នាក់ងារមួយចំនួន ធ្វើឲ្យស្ត្រីយល់ខុសអំពីការរៀបចំការងារ របស់ពួកគេ ឬខកខានក្នុងការផ្តល់ព័ត៌មានសំខាន់ៗស្តីពីការស្វែងរកជំនួយក្នុងករណីដែល មានបញ្ហានៅក្នុងប្រទេសម៉ាឡេស៊ី។ ស្ត្រីនិងកុមារីដែលបានសម្ភាសន៍ គ្មានអ្នកណាម្នាក់បាន ទទួលកិច្ចសន្យាជួលធ្វើការងាររបស់ខ្លួន ជាមួយទីភ្នាក់ងារជ្រើសរើសពលករក្នុងប្រទេសកម្ពុជា ទេ ឬជាមួយនិយោជករបស់ពួកគេនៅប្រទេសម៉ាឡេស៊ីទេ។

ប្រាក់ឈ្នួលសម្រាប់ការជ្រើសរើសដ៏ស្មុគ្រស្មាញ និងការអនុវត្តការឲ្យខ្ចីប្រាក់ដែលនាំឲ្យយល់ខុស បានដាក់អោយមាននូវដំណើរការប្រកបដោយការកេងប្រវ័ញ្ច។ ភ្នាក់ងារជ្រើសរើស ពលករ សំដៅផ្តោះទៅរកគ្រួសារក្រីក្រ និងជូនកាលឲ្យពួកគេខ្ចីជាសាច់ប្រាក់សុទ្ធត្រង់ៗ និង អង្ករ ដើម្បីជាការជម្រុញទឹកចិត្តពួកគេអោយធ្វើចំណាកស្រុក។ អ្នកធ្វើចំណាកស្រុកត្រូវតែសង ប្រាក់កម្ចីទាំងអស់នេះវិញ រួមជាមួយនឹងថ្លៃឈ្នួលហួសប្រមាណលើការហ្វឹកហ្វឺន និងការរក ការងារឲ្យធ្វើ ដោយការប្រគល់ប្រាក់ចំនួន ប្រាំមួយ ទៅប្រាំពីរខែដំបូង នៃប្រាក់ខែរបស់ពួកគេ ដល់ទីភ្នាក់ងារជ្រើសរើសពលករ នៅពេលដែលពួកគេចាប់ផ្តើមធ្វើការក្នុងប្រទេសម៉ាឡេស៊ី។ ការរៀបចំនេះ ធ្វើឲ្យមានការលំបាកសម្រាប់ពលករម្នាក់ ក្នុងការចាកចេញពីទីកន្លែងការងារ របស់ខ្លួនក្នុងប្រទេសម៉ាឡេស៊ី ប្រសិនបើនាងជួបប្រទះការរំលោភបំពាន។

ប្រសិនបើពលករម្នាក់ផ្លាស់ប្តូរគំនិតរបស់ខ្លួន ពីការធ្វើចំណាកស្រុកខណៈពេលដែលកំពុងស្ថិតនៅក្នុងការហ្វឹកហ្វឺនក្នុងប្រទេសកម្ពុជា នាងត្រូវតែសងប្រាក់កម្ចីដំបូងៗ រួមទាំងថ្លៃរស់នៅក្នុងមណ្ឌលហ្វឹកហ្វឺន និងប្រាក់ឈ្នួលរត់ការឯកសារនានា។ ភ្នាក់ងារជ្រើសរើសពលករ ជាញឹកញយគណនាថ្លៃឈ្នួលខ្ពស់ជាងតម្លៃពិត

ដោយបំបោងបំណុលសារុបរបស់ពលករចំណាក ស្រុក។ អ្នកត្រៀមធ្វើចំណាកស្រុកភាគច្រើន មកពីគ្រួសារដែលក្រីក្រ និងមិនអាចបង់ប្រាក់ ដែលជាធម្មតាមានចំនួនពី ៣០០ដុល្លារ ទៅ៥០០ដុល្លារ ហើយជាប្រការមួយដែលធ្វើឲ្យពួកគេ គ្មានជម្រើសអ្វីក្រៅតែពីការធ្វើចំណាកស្រុក។

នៅក្នុងការហ្វឹកហ្វឺនក្នុងប្រទេសកម្ពុជា ភ្នាក់ងារជ្រើសរើសពលករ ដាក់កំហិតលើសេរីភាព ដើរហើររបស់អ្នកត្រៀមធ្វើចំណាកស្រុក និងដាក់កំហិតលើការទាក់ទងរបស់ពួកគេជាមួយ ក្រុមគ្រួសារ រហូតទាល់តែពួកគេចាកចេញទៅប្រទេសម៉ាឡេស៊ី។ ពួកគេអាចទទួលរងនូវការ រំលោភបំពានដោយពាក្យសម្តី ការរំលោភខាងផ្លូវចិត្ត និងជួនកាលរងការរំលោភខាងផ្លូវកាយ។ អ្នកដែលគេបានជ្រើសរើស ដែលត្រូវបានសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្សបាន ពិពណ៌នាមណ្ឌលហ្វឹងហ្វឺនទាំងនោះថា មានមនុស្សច្រើនកកកុញ និងមានស្ថានភាពរស់នៅ មិនល្អ ដោយគ្មានសិទ្ធិទទួលបានអាហារហូបចុក ទឹក និងការថែទាំជំងឺគ្រប់គ្រាន់ទេ។ ពួកគេ និយាយថា ភ្នាក់ងារជ្រើសរើសពលករជាញឹកញយបដិសេធមិនផ្តល់ការថែទាំដល់ពលករ ដែលមានជំងឺឲ្យបានត្រឹមត្រូវទេ និងប្រសិនបើ គេបញ្ជូនពលករទៅមន្ទីរសម្រាកព្យាបាល នោះ ពួកគេបូកបន្ថែមចំណាយលើការព្យាបាលនោះទៅក្នុងបំណុលរបស់ពលករ។

## ក្នុងប្រទេសម៉ាឡេស៊ី

ខណៈពេលដែលនៅក្នុងប្រទេសម៉ាឡេស៊ី ស្ត្រីនិងកុមារីកម្ពុជាប្រឈមនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ច ជាញឹកញយពួកគេមានសមត្ថភាពដ៏មានកម្រិត ឬមិនមានសមត្ថភាពក្នុង ការធ្វើទំនាក់ទំនងតាមរយៈភាសាអង់គ្លេស ឬភាសាម៉ាឡេស៊ីទេ ប្រការនេះធ្វើឲ្យពួកគេត្រូវតែ លះបង់លិខិតឆ្លងដែនរបស់ពួកគេទៅឲ្យទីភ្នាក់ងាររបស់ពួកគេ ឬទៅឲ្យនិយោជក ហើយធ្វើឲ្យ ពួកគេខ្វះខាត នូវព័ត៌មានដើម្បីចរចារអំពីលក្ខខ័ណ្ឌការងារនិងប្រាក់ខែ។ ការរំលោភបំពាននៅ កន្លែងការងារជាទូទៅបំផុត ដែលតាមពលករធ្វើការតាមផ្ទះជាតិកម្ពុជា បានរាយការណ៍ដល់ អាជ្ញាធរ អង្គការក្រៅរដ្ឋាភិបាល និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស មានជាអាទិ៍ ការឲ្យធ្វើការងារ ច្រើនម៉ោងហួសហេតុ ដោយគ្មានថ្ងៃឈប់សម្រាក កង្វះខាតអាហារហូបចុក និងប្រាក់បៀវត្សរ៍ មិនទៀងទាត់ ឬមិនមានប្រាក់បៀវត្សរ៍។

ពលករធ្វើការតាមផ្ទះជាតិកម្ពុជា និងឥណ្ឌូនេស៊ី ជាធម្មតារកប្រាក់ចំណូលប្រចាំខែបានពី៤០០ទៅ៦០០ រីងហ្គីត (១៣៣ ដុល្លារ ទៅ ២០០ដុល្លារ)។ ពលករខ្លះបានរាយការណ៍ឲ្យអង្គការឃ្លាំមើលសិទ្ធិមនុស្សដឹងអំពី ការរំលោភខាងផ្លូវភេទនិងផ្លូវកាយ និងការដាក់កំហិតលើសេរីភាព ក្នុងការដើរហើរ និងសេរីភាពក្នុងការធ្វើទំនាក់ទំនងរបស់ពួកគេ។ ក្នុងករណីខ្លះ ស្ត្រីនិងកុមារី បានធ្លាក់ចូលក្នុង ស្ថានភាពពលកម្មដោយបង្ខំ និងការជួញដូរ។ អ្នកទាំងឡាយដែលបាន គេចខ្លួនចេញពីនិយោជកដែលរំលោភបំពាន បានប្រថុយប្រថាននឹងការប្រព្រឹត្តមកលើខ្លួន ក្នុងនាមជាអ្នកប្រព្រឹត្តបទល្មើសអន្តោប្រវេសន៍ក្នុងប្រទេសម៉ាឡេស៊ី ដែលធ្វើឲ្យមានការពិបាក ក្នុងការទាមទារមកវិញនូវប្រាក់បៀវត្សរ៍ដែលមិនទាន់បានបង់អោយដោយនិយោជក និងដាក់ ឲ្យពួកគេងាយរងគ្រោះពីការចាប់ខ្លួន ឃុំខ្លួន និងនិរទេស ។

ស្ថានទូតកម្ពុជាក្នុងប្រទេសម៉ាឡេស៊ី ខ្វះខាតបុគ្គលិកគ្រប់គ្រាន់ ទេពកោសល្យ និងធនធាន ដើម្បីជួយដោះស្រាយអោយអ្នកធ្វើការតាមផ្ទះ ដែលមកតវ៉ាអំពីការរំលោភបំពាន។ ស្ថានទូត ទទួលបាន បណ្ដឹងតវ៉ាចំនួន ៨០ នៅក្នុងឆ្នាំ២០១០ ដែលមានបុគ្គលិកធ្វើការមិនពេញម៉ោង តែម្នាក់គត់ ដែលកាន់កាប់ដោះស្រាយបណ្ដឹងទាំងនោះ និងបានចាប់ផ្ដើមផែនការឲ្យមានជម្រក នៅនឹងកន្លែងមួយក្នុងខែកញ្ញា ឆ្នាំ២០១១។ បញ្ហាមួយនៃបញ្ហាដ៏ធ្ងន់ធ្ងរបំផុតនោះ គឺការ អនុវត្តន៍របស់ស្ថានទូត ក្នុងការ បញ្ជូនពលករដែលទទួលរងនូវការរំលោភបំពាន ត្រឡប់ទៅ ទីភ្នាក់ងាររបស់ពួកគេវិញ ជំនួសអោយការកាន់ ករណីនោះដោយខ្លួនឯង។ ទីភ្នាក់ងារខ្លះ ដាក់ឲ្យស្ត្រីទាំងនេះធ្វើការងារឲ្យនិយោជកទីពីរ ឬទីបីផ្ទុយនឹងឆន្ទះរបស់ពួកគេ។

ប្រទេសម៉ាឡេស៊ី បានផ្ដល់ការធានាជាអប្បរមាមួយចំនួនតូចដល់អ្នកធ្វើការតាមផ្ទះ។ ច្បាប់ការងារម៉ាឡេស៊ី ដាក់ពលករធ្វើការតាមផ្ទះ អោយនៅក្រៅកិច្ចការពារខាងពលកម្មសំខាន់ៗ មានដូចជាសំណង សម្រាប់របួសស្នាមនៅកន្លែងធ្វើការ ថ្ងៃសម្រាកប្រចាំសប្ដាហ៍ ប្រាក់ការងារ លើសម៉ោង និងការ កំណត់ចំនួនម៉ោងប្រចាំសប្ដាហ៍។ ការមិនមាននិយាយកំណត់អំពីការ កាត់ប្រាក់ខែ បាននាំឲ្យ មានការអនុវត្តន៍បែបកេងប្រវ័ញ្ច ដោយការកាត់ប្រាក់ខែពី ប្រាំមួយ ទៅ ប្រាំពីរខែដំបូងនៃប្រាក់ខែ របស់អ្នកធ្វើការតាមផ្ទះជាតិកម្ពុជា - ចេញពីកិច្ចសន្យាការងាររយៈ ពេលពីរឆ្នាំ - ដើម្បីសងថ្លៃជ្រើសរើស។ រដ្ឋាភិបាលប្រទេសម៉ាឡេស៊ីបានបញ្ចប់អនុស្សរណៈ យោគយល់គ្នាមួយជាមួយប្រទេសឥណ្ឌូនេស៊ី ក្នុងខែឧសភា ឆ្នាំ២០១១ ដើម្បីធានាដល់ពលករ ចំណាកស្រុកធ្វើការតាមផ្ទះ នូវលទ្ធភាពរក្សាលិខិតឆ្លងដែនរបស់ខ្លួន និងទទួលបានថ្ងៃឈប់ សម្រាកប្រចាំសប្ដាហ៍ ប៉ុន្តែមិនបានពង្រីកកិច្ចការពារទាំងនេះ ដល់ពលករចំណាកជាតិកម្ពុជា នោះទេ។



រូបថតរបស់ស្ត្រីម្នាក់ដែលម្តាយនាងបានចែករំលែកជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ នាងម៉ាលី (ឈ្មោះពិតត្រូវបានដកចេញ) ជាម្តាយម្នាក់ ដែលបានធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ីក្នុងខែមេសា ឆ្នាំ២០១០ និងតាំងពីនោះមក មិនដែលបានទាក់ទងជាមួយគ្រួសាររបស់នាងទេ។ នាងបានទុកកូនស្រីអាយុប្រាំមួយឆ្នាំ និងកូនប្រុសអាយុប្រាំពីរឆ្នាំរបស់នាងឲ្យរស់នៅជាមួយនឹងម្តាយរបស់នាង និងសន្យាផ្ញើរប្រាក់ពីប្រទេសម៉ាឡេស៊ីមកដើម្បីជួយដល់ ពួកគេ។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។



ពិធីបុណ្យសព ឈឹម សុភាព ស្ត្រីអាយុ៣៦ឆ្នាំ ដែលបានស្លាប់ក្នុងមណ្ឌលហ្វឹកហ្វឺនក្នុងរាជធានីភ្នំពេញ ក្នុងខែកុម្ភៈ ឆ្នាំ២០១១។ កូនប្រុសរបស់នាង បានកាន់រូបថតនាងឈឹម សុភាព ជាការផ្តល់ការលាម្តាយជាចុងក្រោយ។ ស្ត្រីបីនាក់បានស្លាប់ក្នុងមណ្ឌលហ្វឹកហ្វឺនក្នុងឆ្នាំកន្លងទៅ។ មកដល់ពេលនៃការចេញរបាយការណ៍នេះ មិនមានមរណភាពណាមួយត្រូវបានគេធ្វើការ ស៊ើបអង្កេតឲ្យបានពេលលេញទេ។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។

## រដ្ឋាភិបាលកម្ពុជា

រដ្ឋាភិបាលកម្ពុជាកំពុងជំរុញដល់ការងារចំណាកស្រុកទៅក្រៅប្រទេសយ៉ាងខ្លាំងក្លា ដែលជា យុទ្ធសាស្រ្តមួយបង្កើនប្រាក់ផ្ញើរពីបរទេស ដើម្បីដោះស្រាយភាពអត់ការងារធ្វើ និងសម្រាល ភាពក្រីក្រ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបោះបង់ចោលការទទួលខុសត្រូវរបស់ខ្លួនភាគច្រើន ដើម្បីការពារអ្នកចំណាកស្រុក ដោយទុកឲ្យទីភ្នាក់ងារឯកជនជាអ្នកធ្វើការទទួលខុសត្រូវនេះ។ ទីភ្នាក់ងារជ្រើសរើសពលករធំៗមួយចំនួន មានម្ចាស់ជាមន្រ្តីមានអំណាចបំផុតរបស់រដ្ឋាភិបាល ឬ មានជាប់ទាក់ទងជាមួយមន្រ្តីរដ្ឋាភិបាលដ៏មានអំណាចបំផុតមួយចំនួននៅក្នុងប្រទេស។ ការ ជាប់ទំនាក់ទំនងដ៏ជិតស្និទបែបនេះ រួមទាំងឥទ្ធិពល ធ្វើឲ្យមានការលំបាកដល់អ្នកធ្វើអធិការកិច្ចការងារ នគរបាល ឬមន្រ្តីដទៃទៀតក្នុងការស៊ើបអង្កេតបណ្តឹងតវ៉ាឲ្យបានពេញលេញ ឬដាក់ទីភ្នាក់ជ្រើសរើសពលករឲ្យ ទទួលខុសត្រូវចំពោះអំពើកេងប្រវ័ញ្ច។ ជាក់ស្តែង អ្នកធ្វើការតាមផ្ទះមិនមានផ្លូវរកវិធីដោះស្រាយ ដែលមានប្រសិទ្ធិភាពបានទេ ដោយភ័យខ្លាចពីការសង សឹកតបវិញ ឬខ្វះខាតធនធាន ឬជំនឿលើ ស្ថាប័នរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហារបស់ ពួកគេ។

ចំពោះមុខស្ថានភាពនេះ រដ្ឋាភិបាលកម្ពុជាបានខ្វះខាតឱកាសក្នុងការលើកកំពស់កិច្ចការពារសិទ្ធិ មនុស្សសម្រាប់ពលករចំណាកស្រុក នៅពេលដែលខ្លួនចេញសេចក្តីកែប្រែបទបញ្ជារ ការងារមួយសម្រាប់ទីភ្នាក់ងារជ្រើសរើសពលករ ក្នុងខែសីហា ឆ្នាំ២០១១។ ថ្វីបើរដ្ឋាភិបាល បានអញ្ជើញឲ្យមានការផ្តល់គំនិតយោបល់ ពីសមាគមទីភ្នាក់ងារជ្រើសរើសពលករជាតិកម្ពុជា និងពីក្រុមឧស្សាហកម្មក៏ដោយ ក៏រដ្ឋាភិបាលមិនបានពិភាក្សាជាមួយអង្គការក្នុងស្រុក ឬអង្គការ អន្តរជាតិ ក្នុងអំឡុងនៃការកែប្រែអនុក្រិត្យឆ្នាំ១៩៩៥នោះដែរ។ អនុក្រិត្យនោះកំណត់ពីការ ទទួលខុសត្រូវរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការធ្វើអធិការកិច្ចលើ ទីភ្នាក់ងារជ្រើសរើសពលករ និងណែនាំឲ្យ មានការផ្លាស់ប្តូរមួយចំនួន ដូចជាតម្រូវឲ្យ ទីភ្នាក់ងារជ្រើសរើសពលករ ផ្តល់នូវកិច្ចសន្យាជាភាសាខ្មែរ និងផ្តល់មេធាវីសម្រាប់អ្នកធ្វើ ចំណាកស្រុកដែលប្រឈមមុខនឹងនីតិវិធីខាងផ្លូវច្បាប់នៅបរទេស។ ប៉ុន្តែ អនុក្រិត្យនេះ មិនបាននិយាយបញ្ជាក់អំពី តម្រូវការអប្បបរមាសម្រាប់មណ្ឌលហ្វឹកហ្វឺន និងមិនបានបង្កើតឲ្យ មាននូវយន្តការនៃការតវ៉ាប្រកបដោយប្រសិទ្ធិភាព ឬយន្តការតាមដានឃ្លាំមើលនោះទេ។

នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ រដ្ឋាភិបាលកម្ពុជាបានប្រកាសអោយបញ្ឈប់ការបញ្ជូនពលករ ធ្វើការតាមផ្ទះទៅប្រទេសម៉ាឡេស៊ី។ ទោះបីជាមានការប្រកាសបែបនេះក្តី ក្នុងពេលសរសេរ របាយការណ៍នេះ ក្រុមអង្គការសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា ទីភ្នាក់ងារ ជ្រើសរើសពលករមួយចំនួនមិនអើពើចំពោះការហាមឃាត់នេះទេ។ ខណៈដែរ ការហាមឃាត់ ជាបណ្តោះអាសន្ននេះ គឺជាវិធានការវិជ្ជមានមួយ បើសិនជាត្រូវបានប្រើប្រាស់ដើម្បីចរចារ និង អនុវត្តកំណែទម្រង់នានាអោយកាន់តែគ្រប់ជ្រុងជ្រោយនោះ ប៉ុន្តែការហាមឃាត់បែបនេះតែ ឯកឯងដូចដែលបានដាក់ចេញនៅក្នុងប្រទេសដទៃដែរ គំរនឹងមានប្រសិទ្ធភាពណាស់។ ការ ហាមឃាត់ទាំងនេះ នឹងដាក់កំហិតដល់ឱកាសការងាររបស់ស្រ្តី និងការខកខានដោះស្រាយ ចំពោះមូលហេតុនៃការកេងប្រវ័ញ្ច ដូចជា

ភាពចន្លោះប្រហោងនៃការការពារផ្នែកច្បាប់ នោះវា
អាចជំរុញអោយពលករធ្វើការងារតាមផ្ទះធ្វើចំណាកស្រុកក្រៅបណ្ដាញផ្លូវការ ដែលធ្វើអោយ
ពួកគេប្រឈមមុខនឹងគ្រោះថ្នាក់នៃការរំលោភបំពានកាន់តែខ្លាំងឡើង។

## កាតព្វកិច្ច

ប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី បានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងអនុសញ្ញាស្ដីពី
ការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ជាភាគីទៅនឹង សន្ធិសញ្ញាទាំងនេះ
ក៏ដូចជាកិច្ចការពារតាមច្បាប់ទម្លាប់អន្តរជាតិ ប្រទេសកម្ពុជា និងប្រទេស ម៉ាឡេស៊ី មានកាតព្វ
កិច្ចការពារសិទ្ធិស្ត្រីនិងកុមារ ដែលធ្វើចំណាកស្រុកជាអ្នកធ្វើការតាមផ្ទះ រួមទាំងកាតព្វកិច្ចប្រឆាំងការ
រើសអើងក្នុងវិស័យការងារ ការងារដោយបង្ខំ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមារ។

បទដ្ឋានពិភពលោកថ្មី បង្ហាញអំពីកាតព្វកិច្ចជាក់លាក់របស់រដ្ឋាភិបាល ក្នុងកិច្ចការពារពលករធ្វើការតាមផ្ទះ
ជាក្រុមមួយដែលជាប្រវត្តិសាស្ត្រ មិនត្រូវបានគិតគូរដល់នៅក្នុងច្បាប់ការងារ។ ក្នុងខែមិថុនា ឆ្នាំ២០១១
អង្គការពលកម្មអន្តរជាតិ បានអនុម័តអនុសញ្ញាលេខ១៨៩ ស្ដីពី ការងារសមស្របសម្រាប់អ្នកធ្វើការតាមផ្ទះ។
ទោះជាប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី មិនទាន់ឲ្យសច្ចាប័នលើសន្ធិសញ្ញាថ្មីនេះក៏ដោយ
ក៏អនុសញ្ញានេះផ្ដល់ជាមគ្គុទ្ទេសក៏ដ៏មានតម្លៃ ស្ដីពីបទដ្ឋានអប្បបរមាដែលប្រទេសទាំងពីរគួរតែអនុវត្តន៍តាម។
ទាំងនេះមានរាប់បញ្ចូលទាំង កិច្ចការពារការងារដែលមានលក្ខណៈសមមូល ដូចដែលផ្ដល់ដល់កម្មករដទៃទៀត
ការទៅប្រើ ប្រាស់បានយន្តការសម្រាប់ការប្ដឹងតវ៉ា ទណ្ឌកម្មធ្ងន់ធ្ងរចំពោះទីភ្នាក់ងារដែលរំលោភបទដ្ឋាន
និងហាមឃាត់ការកាត់ប្រាក់ខែសម្រាប់ថ្លៃឈ្នួលជ្រើសរើសពលករ។

រដ្ឋាភិបាលកម្ពុជា និងម៉ាឡេស៊ី គួររៀបចំនូវការកែទម្រង់ គោលនយោបាយខាងការងារ និង ចំណាកស្រុកឲ្យមាន
លក្ខណៈទូលំទូលាយ និងរៀបចំអោយមាននូវ ការទទួលបានសេវាគាំទ្រ ប្រកបដោយប្រសិទ្ធិភាព និងមធ្យោ
បាយដោះស្រាយបញ្ហារំលោភបំពាន ក្នុងប្រទេសទាំងពីរ ដើម្បីធានាដល់កិច្ចការពារសិទ្ធិរបស់អ្នក
ធ្វើការងារតាមផ្ទះដែលចំណាកស្រុក និងដើម្បីធានា ឲ្យស្របទៅតាមច្បាប់អន្តរជាតិ។

# អនុសាសន៍

## ជូនចំពោះរដ្ឋាភិបាលកម្ពុជា

### *ចំពោះរដ្ឋសភា*

**អនុម័តច្បាប់ការពារពលករចំណាកស្រុក រួមទាំងអ្នកធ្វើការតាមផ្ទះ**

- អនុម័តច្បាប់ស្តីពីចំណាកស្រុក ដែលមានលក្ខណៈទូលំទូលាយ ដែលដោះស្រាយកង្វល់សំខាន់ៗ ដូចជាការត្រួតពិនិត្យមើលលើទីភ្នាក់ងារជ្រើសរើសពលករ បញ្ហាប្រាក់ឈ្នួលជ្រើសរើស និងប្រាក់បំណុល ការតាមដានឃ្លាំមើលមណ្ឌលហ្វឹកហ្វឺន និងការ ជ្រើសរើសកុមារ។
- ធានាឲ្យមានការពិភាក្សាយ៉ាងទូលំទូលាយជាមួយអង្គការក្នុងស្រុកនិងអង្គការអន្តរជាតិ ដែលកំពុងតែបំពេញការងារលើការធ្វើចំណាកស្រុក និងការជួញដូរ។
- បញ្ចូលការដាក់ទណ្ឌកម្មធ្ងន់ធ្ងរសម្រាប់អំពើរំលោភបំពាន ដោយមានជាមួយនូវ យន្តការច្បាស់លាស់ និងប្រកបដោយប្រសិទ្ធិភាពសម្រាប់ការឃ្លាំមើល និងការ ប្រតិបត្តិ។
- ធ្វើការជាមួយប្រទេសបញ្ជូនពលករ ដូចជាប្រទេស ឥណ្ឌូណេស៊ី ដើម្បីទទួលបាននូវ ការការពារអប្បរមាសម្រាប់ពលករចំណាកស្រុកដែលធ្វើការងារតាមផ្ទះនៅបរទេស។

### *ចំពោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ*

**ពង្រឹងច្បាប់ និងឃ្លាំមើលទីភ្នាក់ងារជ្រើសរើសពលករ**

- បង្កើតយន្តការសម្រាប់ការធ្វើអធិការកិច្ចទៀងទាត់ និងមិនប្រកាសឲ្យដឹងជាមុន និងប្រតិបត្តិកិច្ចការពារដែលមានកំណត់ក្នុងច្បាប់ការងារ ច្បាប់បង្ក្រាបការជួញដូរមនុស្ស និងបទបញ្ជារបស់ក្រសួង រួមទាំងការហាមឃាត់មិនឲ្យមានផ្តល់ប្រាក់សុទ្ធ ជាមុន និងប្រាក់កម្ចី ដើម្បីលួងលោមពលករអោយធ្វើចំណាកស្រុក។
- ធានាថា បទបញ្ជារបស់ទីភ្នាក់ងារជ្រើសរើសពលករឯកជន ស្របតាមបទដ្ឋាន ដែលបានបង្កើតក្នុងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៨៩ ស្តីពីការងារសម ស្របសម្រាប់អ្នកធ្វើការងារតាមផ្ទះ រួមមានការចុះបញ្ជី ការបង្កើតនូវយន្តការប្តឹងតវ៉ា ដែលងាយទៅរកប្រើប្រាស់បាន និងហាមឃាត់ការកាត់ប្រាក់ខែ ដើម្បីបង់ថ្លៃឈ្នួល ជ្រើសរើសពលករ។
- អនុវត្តទោសបញ្ញត្តិដែលមានស្រាប់ដូចជា ការលុបចោលអាជ្ញាប័ណ្ណ និងការរឹបអូសប្រាក់ធានា១០០,០០០ ដុល្លារ ក្នុងករណីប្រព្រឹត្តកិរិយាមិនត្រឹមត្រូវ និងរំលោភបំពាន។
- ផ្សព្វផ្សាយឈ្មោះរបស់ទីភ្នាក់ជ្រើសរើសពលករដែលទទួលទណ្ឌកម្ម។
- ធ្វើការជាមួយអាជ្ញាធរប្រតិបត្តិច្បាប់ ដើម្បីគាំទ្រឲ្យមានការស៊ើបអង្កេតរហ័ស មិនលំអៀង និងមានតម្លាភាព ក្នុងបទចោទប្រកាន់អំពី អំពើរំលោភសិទ្ធិមនុស្សលើពលករត្រៀមធ្វើចំណាកស្រុក ដែលប្រព្រឹត្តដោយទីភ្នាក់ងារជ្រើសរើសពលករ រួមទាំង មរណភាព និងការរបួសធ្ងន់ធ្ងររបស់ពលករក្នុងមណ្ឌលហ្វឹកហ្វឺន។

ពង្រឹងច្បាប់ និងឃ្លាំមើលមណ្ឌលហ្វឹកហ្វឺន

- បង្កើតបទដ្ឋានច្បាស់លាស់និងពិស្តារស្តីពី លក្ខខ័ណ្ឌរស់នៅ ការផ្គត់ផ្គង់អាហារ និង ការរៀបចំការងារដែលអាចទទួលយកបាននៅក្នុងមណ្ឌលហ្វឹកហ្វឺន។ ធានាថា សិក្ខាកាម មានសេរីភាពដើរហើរ និងអាចចាកចេញពីមណ្ឌលហ្វឹកហ្វឺនតាមឆន្ទៈ។
- ហាមឃាត់ការអនុវត្តន៍បែបបង្ខិតបង្ខំសិក្ខាកាម និងគ្រួសាររបស់ពួកគេ ឲ្យសងប្រាក់កម្ចី ដើម្បីចាកចេញពីមណ្ឌលហ្វឹកហ្វឺន ឬចាកចេញពីកិច្ចសន្យាការងារ។
- លើកស្ទួយកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងទៃទៀត ដែលផ្តល់ការណែនាំតម្រង់ទិសមុនការចាកចេញ រួមទាំងការហ្វឹកហ្វឺនពីក្របខ័ណ្ឌសិទ្ធិមនុស្ស។
- ធានាសិទ្ធិទទួលបានការថែទាំសុខភាពសម្រាប់សិក្ខាកាម។
- ធានាឲ្យមានការហ្វឹកហ្វឺនមុនការចាកចេញដែលចាំបាច់និងប្រកបដោយប្រសិទ្ធិភាពដែលមានជាអាទ៍ព័ត៌មានអំពីសិទ្ធិរបស់ពលករ និងរបៀបស្វែងរកជំនួយ ហើយដែល ត្រូវផ្តល់ដល់ពលករដោយឥតគិតថ្លៃ។ ប្រើសៀវភៅណែនាំមុនការចាកចេញ ដែល សរសេរចងក្រងឡើង ដោយអង្គការអន្តរជាតិសម្រាប់ការធ្វើចំណាកស្រុក។
- ផ្សព្វផ្សាយព័ត៌មានអំពីយន្តការសម្រាប់ធ្វើបណ្តឹងតវ៉ា និងយន្តការដោះស្រាយ។

បង្កើត និងអនុវត្តន៍ គោលនយោបាយលុបបំបាត់អំពើឃុបឃិតរវាងមន្ត្រីសាធារណៈ និង ទីភ្នាក់ងារជ្រើសរើសពលករ។

- ហាមឃាត់មន្ត្រីរដ្ឋាភិបាលពីការធ្វើជាម្ចាស់ ឬការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ឬការប្រើប្រាស់ឥទ្ធិពលមិនត្រឹមត្រូវ។

បង្កើនសមត្ថភាពប្រតិបត្តិ និងត្រួតពិនិត្យ

- ពង្រឹងសមត្ថភាពត្រួតពិនិត្យតាមរយៈការជ្រើសរើស និងហ្វឹកហ្វឺនបន្ថែមដល់អ្នកធ្វើ អធិការកិច្ចការងារ រួមទាំងអធិការកិច្ចជាស្ត្រី ក្នុងកិច្ចការឃ្លាំមើល និងក្នុងតួនាទីជា អ្នកគ្រប់គ្រង។
- លើកកម្ពស់តម្លាភាពនៃកិច្ចសម្របសម្រួលរបស់អន្តរក្រសួង ជាមួយនឹងក្រសួងរបស់រដ្ឋាភិបាលដទៃទៀត មានជាអាទ៍ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងនគរបាល។
- បង្កើតយន្តការប្តឹងតវ៉ាដែលងាយទៅរកប្រើប្រាស់បាន និងប្រកបដោយការរក្សាការ សម្ងាត់ នៅកម្រិតក្រសួង ដើម្បីឲ្យក្រុមគ្រួសារ និងពលករអាចរាយការណ៍ពីករណី រំលោភបំពាន អំឡុងពេលនៃការជ្រើសរើស និងការហ្វឹកហ្វឺនក្នុងប្រទេសកម្ពុជា និងពី ករណីមិនផ្តល់ប្រាក់ខែ និងការ រំលោភបំពាននៅកន្លែងការងារក្នុងប្រទេសម៉ាឡេស៊ី។

## *ចំពោះក្រសួងមហាផ្ទៃ នគរបាល និងក្រសួងយុត្តិធម៌*

### ធានាឲ្យមានការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សលើពលករធ្វើការតាមផ្ទះដែល ចំណាកស្រុក

- ដឹកនាំការស៊ើបអង្កេតយ៉ាងរហ័ស មិនលំអៀង និងមានតម្លាភាព លើការចោទប្រកាន់ អំពីការរំលោភសិទ្ធិមនុស្សលើពលករចំណាកស្រុក ដោយភ្នាក់ងារជ្រើសពលករ រួមទាំង មរណភាព

និងការរងរបួសធ្ងន់ធ្ងររបស់ពលករដែលត្រៀមធ្វើចំណាកស្រុក ដែលកើតមានឡើងក្នុងមណ្ឌលហ្វឹកហ្វឺន ការបំភិតបំភ័យពលករ និងការក្លែងឯកសារ អត្តសញ្ញាណរបស់កុមារី និងស្ត្រីដែលមិនទាន់គ្រប់អាយុ។

- កាត់ទោសជាបទព្រហ្មទណ្ឌ ចំពោះជនទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើរំលោភសិទ្ធិមនុស្ស។
- បង្កើតកងឯកភាពនគរបាលជាស្ត្រីភេទ ដើម្បីកាន់កាប់ករណីពាក់ព័ន្ធនឹងការរំលោភ បំពានកុមារី និងស្ត្រី ដោយទីភ្នាក់ងារជ្រើសរើសពលករ។
- ធានាឲ្យមាននីតិវិធី ដែលអនុញ្ញាតឲ្យពលករស្វែងរកការដោះស្រាយផ្នែករដ្ឋប្បវេណី រួមទាំងសំណងជួសជុលការខូចខាតជាលុយកាក់ សម្រាប់បណ្ដឹងពីបទប្រព្រឹត្តមិនត្រឹមត្រូវ។

## *ចំពោះក្រសួងការបរទេស*

**ពង្រឹងសមត្ថភាពរបស់ស្ថានទូតកម្ពុជាក្នុងប្រទេសម៉ាឡេស៊ី ដើម្បីជួយដល់ពលករចំណាក ស្រុកដែលធ្វើការតាមផ្ទះ។**

- បញ្ឈប់ជាបន្ទាន់នូវការបញ្ជូនពលករចំណាកស្រុកធ្វើការតាមផ្ទះ ដែលរងការរំលោភ បំពាន ឲ្យវិលត្រឡប់ទៅកាន់ទីភ្នាក់ងារជ្រើសរើសពលកររបស់ពួកគេវិញ។
- ផ្តល់ធនធាន សេវា និងបុគ្គលិកឲ្យបានគ្រប់គ្រាន់ រួមទាំងការផ្តល់ការប្រឹក្សាខាងផ្នែក របួសផ្លូវចិត្ត និងការថែទាំសុខភាព ក្នុងជម្រករបស់ស្ថានទូត ដែលនឹងដាក់ឲ្យប្រតិបត្តិការក្នុងខែតុលា។
- សម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាលកម្ពុជា និងម៉ាឡេស៊ី ដើម្បីផ្តល់ជម្រក ជំនួយផ្នែកច្បាប់ និងសេវាគាំទ្រដទៃទៀត ដល់ពលករដែលទទួលរងការរំលោភ បំពាន។
- បង្កើនចំនួនបុគ្គលិកជាស្ត្រីដែលមានសមត្ថភាព និងមានការហ្វឹកហ្វឺន ដើម្បីកាន់កាប់ កិច្ចការទាក់ទងនឹងទំនាស់ការងារ និងករណីរំលោភបំពាន និងដើម្បីជួយដល់ពលករ ចំណាកស្រុក ធ្វើការតាមផ្ទះ ដែលស្ថិតនៅក្នុងការឃុំឃាំង។
- ធានាថា មន្ត្រីស្ថានទូតធ្វើការងារសម្របសម្រួលយ៉ាងសកម្ម ចំពោះការនាំមកនូវការ កាត់ទោសករណី ព្រហ្មទណ្ឌប្រឆាំងនឹង និយោជកជាតិម៉ាឡេស៊ី និងក្រុមហ៊ុនជ្រើស រើសពលករដែលពាក់ព័ន្ធក្នុងអំពើរំលោភបំពាន និងជួយពលករដាក់ពាក្យបណ្ដឹង រដ្ឋប្បវេណីស្វែងរកសំណង។
- បង្កើតប្រព័ន្ធមួយ ដើម្បីសង្គ្រោះពលករចំណាកស្រុកដែលធ្វើការតាមផ្ទះ ដែលស្ថិត ក្នុង ស្ថានភាពអាសន្ន/គ្រោះថ្នាក់ និងមិនអាចចាកចេញពីស្ថានភាពរំលោភបំពាននោះ រួមទាំង តាមរយៈកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ប្រចាំមូលដ្ឋានដែល ចាំបាច់។

## *ចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ*

- បង្កើតកញ្ចប់សេវាកម្មបន្ថែម មានជាអាទិ៍ ជំនួយផ្នែកច្បាប់ ការថែទាំផ្នែកពេទ្យ ជម្រក ការហ្វឹកហ្វឺនការងារ ឱកាសខាងការអប់រំ ការប្រឹក្សាខាងផ្លូវចិត្ត និងកម្មវិធីសមាហរណកម្ម សម្រាប់ពលករចំណាកស្រុកដែលបានវិលត្រឡប់មកវិញ និងមនុស្សនៅក្នុង បន្ទុករបស់ពួកគេ។
- ធានាថាអោយមាននូវជំនួយបន្ទាន់ដូចជា ការថែទាំផ្នែកពេទ្យ ជំនួយផ្នែកច្បាប់ សេវា ផ្តល់ប្រឹក្សា និង សេវាបញ្ជូន សម្រាប់ពលករចំណាកស្រុក នៅឯព្រលានយន្តហោះ និង នៅតាមចំណុចត្រួតពិនិត្យតាមព្រំដែន សម្រាប់ជនទាំងឡាយដែលត្រឡប់មកកាន់ ប្រទេសកម្ពុជាវិញតាមច្រកមិនផ្លូវការ។

- ជានាឲ្យមានយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាព សម្រាប់កិច្ចសហការ របស់អន្តរក្រសួង រួមទាំងតាមរយៈក្រុមកិច្ចការពិសេស របស់អន្តរក្រសួង ទទួលបន្ទុក បញ្ហាចំណាកស្រុក ដែលបច្ចុប្បន្នមានភាពអសកម្ម ។

### *ចំពោះក្រសួងសុខាភិបាល*

អនុវត្តន៍ច្បាប់ដែលមានស្រាប់ស្តីពីការពិនិត្យសុខភាព ដើម្បីធ្វើឲ្យប្រាកដថា ការពិនិត្យ សុខភាពលើស្ត្រីត្រៀមធ្វើចំណាកស្រុក គឺធ្វើឡើងដោយស្ម័គ្រចិត្ត និងប្រព្រឹត្តទៅតាមការ យល់ព្រមជាមុន។ ធានាថា មានការគោរពចំពោះការសំងាត់ខាងព័ត៌មានស្តីពីសុខភាព ហើយពលករទទួលបានលទ្ធផលពិនិត្យសុខភាពរបស់ពួកគេ។

## ចំពោះសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)

- ដាក់ពិន័យទីភ្នាក់ងារជ្រើសរើសពលករ ដែលពាក់ព័ន្ធនឹងអំពើធ្វើអាជីវកម្ម និងអំពើរំលោភ សិទ្ធិមនុស្សលើពលករចំណាកស្រុក មានជាអាទិ៍ការបណ្តេញចេញពីសមាគម។ បញ្ជូនករណីទៅស្ថាប័នប្រតិបត្តិច្បាប់ និងស្ថាប័នត្រួតពិនិត្យនានា។
- សហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីត្រួតពិនិត្យនានារបស់រដ្ឋាភិបាល ដើម្បីពង្រឹងកម្មវិធីហ្វឹកហ្វឺនមុនការចាកចេញ។
- ចែករំលែកព័ត៌មានអំពីការធ្វើមាតុភូមិនិវត្តរបស់ពលករចំណាកស្រុកធ្វើការតាមផ្ទះ ជាមួយអង្គការនានាដែលធ្វើការងារលើការកេងប្រវ័ញ្ចខាងពលកម្ម និងសិទ្ធិរបស់ ពលករចំណាកស្រុក។ ព័ត៌មានគួររាប់បញ្ចូលនូវសេចក្តីពិស្តារនៃការមកដល់របស់ ពលករដែលបានវិលត្រឡប់មកកម្ពុជាវិញ និងករណីនៃការរំលោភបំពានពលករ ចំណាកស្រុកធ្វើការតាមផ្ទះ។ ការចែករំលែកព័ត៌មាន គួរតែរៀបចំធ្វើឡើងដើម្បីពង្រឹង ការគាំទ្រ និងសេវានានាសម្រាប់ពលករដែលវិលត្រឡប់មកវិញ ដូចជា ការផ្តល់ប្រឹក្សា ទីជម្រក និងជំនួយបន្ទាន់ខាងផ្នែកពេទ្យ។

## ចំពោះរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី

### ពង្រឹងសហប្រតិបត្តិការ ដើម្បីធ្វើអោយប្រសើឡើងដល់យន្តការនៃការធ្វើចំណាកស្រុកដោយ ស្ម័គ្រចិត្ត និងមានសុវត្ថិភាព

- បង្កើតបទដ្ឋានកិច្ចសន្យាដែលអាចអនុវត្តបានទៅវិញទៅមក និងដែលការពារដល់សិទ្ធិ របស់ពលករចំណាកស្រុកធ្វើការតាមផ្ទះ ស្របតាមបទប្បញ្ញត្តជាតិក្នុងច្បាប់ស្តីពី ការងារ និងស្របតាមបទដ្ឋានពលកម្មអន្តរជាតិ និងដោយមានការពិគ្រោះយោបល់ ជាមួយ ក្រុមពលករចំណាកស្រុក បណ្តាប្រទេសដែលបញ្ជូនពលករ ទីភ្នាក់ងាររក ការងារធ្វើ និងអង្គការពលកម្មអន្តរជាតិ។
- ផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨៩ ស្តីពីការងារសមស្រប សម្រាប់ពលករធ្វើការតាមផ្ទះ និងដាក់ច្បាប់ជាតិនិងការប្រតិបត្តិឲ្យស្របតាមនោះ។

- សម្រេចកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការបញ្ជូនពលករចំណាកស្រុកទៅកាន់ប្រទេស ម៉ាឡេស៊ី ឲ្យស្របទៅនឹង អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨៩ អនុសញ្ញា អង្គការពលកម្មអន្តរជាតិស្នូលដទៃទៀត និងអនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញា ស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។
- ធ្វើការតាមរយៈយន្តការតំបន់ ដូចជាកិច្ចដំណើរការកូឡុមបូប្រចាំតំបន់ (Colombo Process) និងបណ្តាប្រទេសបញ្ជូនពលករដទៃៗទៀត ដូចជាហ្វីលីពីន និង ឥណ្ឌូនេស៊ី ដើម្បីលើស្ទួយបទដ្ឋានអប្បបរមាប្រចាំតំបន់សម្រាប់ពលករបម្រើការតាមផ្ទះ។
- ធ្វើសហប្រតិបត្តិការបង្កើតបញ្ជី និងបន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមហ៊ុនជ្រើសរើសពលករ និងមន្ត្រីទីភ្នាក់ងារជ្រើសរើសពលករ ដែលបានរកឃើញគួរឲ្យជឿបានថា មានជាប់ ពាក់ព័ន្ធក្នុង ការអនុវត្តន៍ដោយរំលោភបំពានលើពលករចំណាកស្រុក និងដកហូតយក អាជ្ញាប័ណ្ណរបស់ពួកគេ ដោយផ្តល់ឲ្យពួកគេនូវឱកាសសមស្របមួយដើម្បីធ្វើការតវ៉ា ចំពោះការចុះបញ្ជីរបស់ពួកគេប្រកប ដោយតម្លាភាព។

# ចំពោះរដ្ឋាភិបាលម៉ាឡេស៊ី

## ពង្រីកការការពារដ៏ទូលំទូលាយដល់ពលករធ្វើការតាមផ្ទះ ក្រោមច្បាប់ការងារ

- ធ្វើវិសោធនកម្មច្បាប់ការងារឆ្នាំ១៩៥៥ និងច្បាប់ស្តីពីសំណងសម្រាប់អ្នកធ្វើការ ដើម្បី ផ្តល់កិច្ចការពារខាងការងារដោយស្មើភាព និងទូលំទូលាយ សម្រាប់ពលករធ្វើការ តាមផ្ទះ រួមទាំង បទប្បញ្ញត្តស្តីពីម៉ោងធ្វើការ ថ្ងៃឈប់សម្រាក និងសំណងសម្រាប់ គ្រោះថ្នាក់នៅកន្លែងការងារ និងជំងឺដែលបណ្តាលមកពីការងារ។

## លើកកម្ពស់ការទទួលបានការដោះស្រាយ និងសេវានានាសម្រាប់ជនរងគ្រោះដោយការ រំលោភបំពាន

- បង្កើតយន្តការប្តឹងតវ៉ាដែលងាយទៅរកប្រើប្រាស់បាន សម្រាប់ពលករចំណាកស្រុក ជាតិកម្ពុជា រួមទាំងបង្កើតបណ្តាញទូរស័ព្ទសម្រាប់គ្រាអាសន្ន ដែលមានបុគ្គលិកជា អ្នកនិយាយភាសាខ្មែរ និងអ្នកផ្តល់ព័ត៌មាន នៅឯព្រលានយន្តហោះ។
- ធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់លើការចោទប្រកាន់ពីការជួញដូរមនុស្ស ពលកម្ម ដោយបង្ខំ ការបង្អត់អាហារ ការរំលោភខាងផ្លូវភេទ ការរំលោភលើរាងកាយ និងការ បង្ខាំងពលករចំណាកស្រុកកម្ពុជាដោយបង្ខំ និងកាត់ទោសជនទាំងឡាយដែលរកឃើញថាបានទទួលខុសត្រូវចំពោះអំពើរំលោភបំពានបែបនោះ។
- លុបបំបាត់ចោល ថ្លៃឈ្នួលសម្រាប់ "ប័ណ្ណពិសេស" និងកែប្រែគោលនយោបាយនានា ស្តីពីពលករចំណាកស្រុក ដើម្បីអនុញ្ញាតឲ្យពលករចំណាកស្រុក និងជនរងគ្រោះនៃ អំពើជួញដូរ ស្នាក់នៅ និងរកការងារធ្វើក្នុងប្រទេសម៉ាឡេស៊ី ខណៈពេលនៃការរង់ចាំ ការស៊ើបអង្កេតចប់សព្វគ្រប់ ឬរង់ចាំ បណ្តឹងតវ៉ាជាមួយនាយកដ្ឋានការងារ ឬរង់ចាំការ កាត់ទោសក្នុងករណីព្រហ្មទណ្ឌ។
- ធ្វើកិច្ចសហការយ៉ាងជិតស្និតជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីការពារសិទ្ធិរបស់ ពលករចំណាកស្រុកធ្វើការតាមផ្ទះ មានជាអាទិ៍ តាមរយៈការពិគ្រោះយោបល់ជាទៀងទាត់ ការសម្របសម្រួលការបញ្ជូនលើករណីជាក់លាក់នានា និងការផ្តល់មូលនិធិ។

- ធ្វើអោយប្រសើរឡើងដល់ការការពិនិត្យ ដើម្បីកំណត់អត្តសញ្ញាណអ្នករងគ្រោះដោយការរំលោភបំពានដោយការធ្វើការងារនៅតាមផ្ទះ និងអ្នកនៅរស់រានមានជីវិតពីអំពើ ជួញដូរ និងផ្តល់ឲ្យពួកគេនូវជំនួយផ្នែកច្បាប់ ការប្រឹក្សាយោបល់ និងការស្តារនីតិ សម្បទាដែលចាំបាច់។

ពង្រឹងបទប្បញ្ញត្តច្បាប់ និងឃ្លាំមើលភ្នាក់ងារជ្រើសរើសពលករ
- ហាមឃាត់ការកាត់ប្រាក់បៀវត្សរ៍របស់ពលករ ដើម្បីសងថ្លៃឈ្នួលជ្រើសរើស។
- ដាក់ទណ្ឌកម្មខាងរដ្ឋបាល និងខាងហិរញ្ញវត្ថុឲ្យបានធ្ងន់ធ្ងរចំពោះក្រុមហ៊ុន និង បុគ្គលិករបស់ក្រុមហ៊ុនដែលគេបានរកឃើញថា បានរំលោភបទប្បញ្ញត្តច្បាប់ ដូចជាការរំលោភលើលក្ខខ័ណ្ឌតម្រូវចំពោះអាយុអប្បបរមា សម្រាប់ពលករចំណាកស្រុក ធ្វើការតាមផ្ទះដែលគេបានជ្រើសរើសឲ្យទៅធ្វើនៅប្រទេសម៉ាឡេស៊ី។

## ចំពោះម្ចាស់ជំនួយអន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិ ធានាគារពិភពលោក សហរដ្ឋអាមេរិក និងប្រទេសជប៉ុន

គាំទ្រឲ្យមានតម្លាភាព និងអភិបាលកិច្ចល្អ
- ឧបត្ថម្ភគាំទ្រឲ្យមានរបាយការណ៍ឯករាជ្យមួយ ស្តីពីទំនាស់ផលប្រយោជន៍រវាង ឧស្សាហកម្មជ្រើសរើសពលករ និងមន្ត្រីនៅក្នុងជួររដ្ឋាភិបាលកម្ពុជា។
- ពិនិត្យមើលឡើងវិញលើមូលនិធិ កម្មវិធី និងសកម្មភាពនានា ដែលបានជួយដល់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងនគរបាលប្រឆាំងការជួញដូរមនុស្ស រហូតទាល់តែមានការស៊ើបអង្កេតរបស់រដ្ឋាភិបាលមួយដែលឯករាជ្យ លើមរណភាពនៅឯមណ្ឌលហ្វឹកហ្វឺនពលករ និងរហូតទាល់តែមានការកាត់ទោសជនទាំងឡាយដែលបានរកឃើញថាបានទទួលខុសត្រូវលើបទព្រហ្មទណ្ឌនេះ។
- លើកឡើងនូវកង្វល់អំពីការរំលោភបំពានលើពលករចំណាកស្រុកដែលធ្វើការតាមផ្ទះ នៅក្នុងកិច្ចប្រជុំទ្វេភាគី និងពហុភាគី ជាមួយរដ្ឋាភិបាលកម្ពុជា និងម៉ាឡេស៊ី និងធ្វើការ តស៊ូមតិជាសាធារណៈ ដើម្បីឲ្យមានការកែទម្រង់ប្រកបដោយប្រសិទ្ធិភាព។

ផ្តល់ជំនួយដើម្បីគាំទ្រអ្នកធ្វើចំណាកស្រុក និងអង្គការការពារសិទ្ធិអ្នកចំណាកស្រុក
- ផ្តល់ជំនួយដល់កម្មវិធី និងអង្គការ ដែលផ្តល់សេវាគាំទ្រដល់ពលករចំណាកស្រុកដែល ត្រៀមចេញ និងអ្នកដែលបានវិលត្រឡប់មកវិញ ដែលពួកគេបានទទួលរងគ្រោះដោយ អំពើរំលោភបំពាន រួមមានជំនួយផ្នែកច្បាប់ ការថែទាំសុខភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ ទីជម្រក ការបណ្តុះបណ្តាលលើការងារ និងការប្រឹក្សាផ្នែកផ្លូវចិត្ត។



ស្ត្រីម្នាក់បង្ហាញរូបថតកូនស្រីរបស់គាត់ឈ្មោះ ចន ម៉ាឡៃន ដែលបានថតមុនពេលនាងចាកចេញទៅប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ២០០៩។ នាងត្រូវបានថៅកែរបស់នាងរំលោភទាំងផ្លូវកាយនិងផ្លូវចិត្ត នៅក្នុងប្រទេសម៉ាឡេស៊ី ហើយទីបំផុតនាងបានព្យាយាមធ្វើអត្តឃាត។ នាងបានរស់រានមានជីវិត ប៉ុន្តែមានរបួសធ្ងន់ធ្ងរ ហើយក្រោយមកថៅកែរបស់នាងបានបញ្ជូននាងឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ។ ឪពុករបស់នាងបាននិយាយថា នៅពេលដែល ម៉ាឡៃន ត្រឡប់មកផ្ទះវិញ នាងមានសតិ "មិនប្រក្រតី" ទេ និងមិនស្គាល់ទាំងម្តាយខ្លួនឯងទៀតផង។ ស្ត្រីនិងកុមារីកម្ពុជាជាច្រើន ប្រឈមមុខនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានពីនិយោជក ឬពីភ្នាក់ងារជ្រើសរើសពលករក្នុងប្រទេសម៉ាឡេស៊ី។ ពួកគេទទួលបានជំនួយផ្នែកច្បាប់ និង ការថែទាំសុខភាពដ៏មានកំរិតជាទីបំផុត នៅក្នុងប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី។ © 2011 យូសនា ពូយ៉ាល/អង្គការឃ្លាំមើលសិទ្ធិមនុស្ស។